ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ០១១៣ ព.ណ.ជ.ក

ភ្នំពេញ, ថ្ងៃទី១៣ ខែ មករា ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ឆ្នាំ ២០១២

ក្រសួងពាណិជ្ជកម្មសូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងសាធារណៈជនឱ្យបានជ្រាបថា ៖ ក្រសួងពាណិជ្ជកម្មនឹងធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងសម្រាប់ឆ្នាំ២០១២នេះ **ចំនួន ៦៩កន្លែង** ដើម្បីបំពេញការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងនៅទីស្តីការក្រសួង ដូចខាងក្រោម ៖

**ក-** សម្រាប់បម្រើការងារនៅមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត ចំនួន ១៦កន្លែង ៖

| លរ | មន្ទីរពាណិជ្ជកម្ម | ក្របខ័ណ្ឌ | | លរ | មន្ទីរពាណិជ្ជកម្ម | ក្របខ័ណ្ឌ | | លរ | មន្ទីរពាណិជ្ជកម្ម | ក្របខ័ណ្ឌ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ក | ខ | | | ក | ខ | | | ក | ខ |
| ១ | ខេត្តកណ្តាល | ១ | | ៥ | ខេត្តបាត់ដំបង | ១ | | ៩ | ខេត្តរតនគិរី | ១ | |
| ២ | ខេត្តកំពត | ១ | | ៦ | ខេត្តសៀមរាប | ១ | | ១០ | ខេត្តកំពង់ធំ | ១ | |
| ៣ | ខេត្តស្វាយរៀង | ១ | | ៧ | ខេត្តកោះកុង | | ១ | ១១ | ខេត្តព្រៃវែង | ១ | |
| ៤ | ខេត្តកំពង់ឆ្នាំង | ១ | | ៨ | ខេត្តឧត្តរមានជ័យ | ១ | | ១២ | រាជធានីភ្នំពេញ | ៣ | ២ |

**ខ-** សម្រាប់បម្រើការងារនៅទីស្តីការក្រសួង ចំនួន ៥៣កន្លែង រួមមាន៖

. ជំនាញខាងគីមីសាស្ត្រ ជីវរូបសាស្ត្រ កម្រិតមធ្យមឯកទេស ចំនួន ០៥ កន្លែង
. ជំនាញខាងព័ត៌មានវិទ្យា កម្រិតបរិញ្ញាប័ត្រឡើងទៅ ចំនួន ១០ កន្លែង
. ជំនាញខាងសេដ្ឋកិច្ច ពាណិជ្ជកម្ម គ្រប់គ្រង នីតិកម្ម សវនកម្ម គណនេយ្យ ហិរញ្ញវត្ថុ ភាសាអង់គ្លេស រដ្ឋបាលទូទៅ កម្រិតបរិញ្ញាប័ត្រឡើងទៅ ចំនួន ៣៨ កន្លែង។

**គ- លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស :**

១- បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ជាតិខ្មែរ
២- បេក្ខជនដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌ «ក» គឺជាបេក្ខជនដែលមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ឬសញ្ញាប័ត្រមានតម្លៃសមមូល និងត្រូវមានអាយុមិនលើសពី ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

៣- ចំពោះបេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌ «**ខ**» គឺជាបេក្ខជនដែលមានសញ្ញាប័ត្រចាប់ពីកំរិតមធ្យមសិក្សាឯកទេសឡើងទៅ (បរិញ្ញាប័ត្ររង) ឬសញ្ញាប័ត្រមានតម្លៃសមមូល និងត្រូវមានអាយុមិនលើសពី ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

៤- បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាបឋមលើជំនាញកុំព្យូទ័រ (Microsoft Word & Excel) ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រឹមត្រូវ។

៥- បេក្ខជនជាជនពិការមានសមត្ថភាពសមស្រប និងបេក្ខជនជានារី ត្រូវបានលើកទឹកចិត្ត។

**ឃ- កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង :**

- ការទទួលពាក្យសុំចុះឈ្មោះប្រឡង នឹងប្រព្រឹត្តទៅនៅរៀងរាល់ម៉ោងធ្វើការ ចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះ រហូតដល់ **ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១២** ត្រឹមវេលាម៉ោង១៧:០០ ជាកាលបរិច្ឆេទចុងក្រោយ។
- បេក្ខជន ត្រូវសរសេរ និងបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡង ហើយត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងដោយខ្លួនឯង នៅតាមទីកន្លែងកំណត់ ៖
  . បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែង ចូលបម្រើការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត អាចដាក់ពាក្យនៅតាមមន្ទីរពាណិជ្ជកម្ម ឬនៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួង (នាយកដ្ឋានបុគ្គលិក)
  . បេក្ខជន ដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងចូលបម្រើការងារនៅទីស្តីការក្រសួង ត្រូវមកដាក់ពាក្យនៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡង (នាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម)

**ង- សំណុំលិខិតសុំចុះឈ្មោះប្រឡង :**

| | |
|---|---|
| ១-ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែមប្រ៊ីយ៍ | ចំនួន ០១ ច្បាប់ |
| ២-ច្បាប់ចម្លងសញ្ញាប័ត្រដែលមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |
| ៣-ជីវប្រវត្តិសង្ខេបមានបិទរូបថត ៤ X ៦ | ចំនួន ០១ ច្បាប់ |
| ៤-សលាកប័ត្រឯកត្តជន | ចំនួន ០២ ច្បាប់ |
| ៥-រូបថតថ្មី ៤ X៦ (ថតចំពីមុខ) | ចំនួន ០២ សន្លឹក |
| ៦-បង្កាន់ដៃទទួលពាក្យ | ចំនួន ០២ ច្បាប់ |
| ៧-កិច្ចសន្យា | ចំនួន ០១ ច្បាប់ |
| ៨-ច្បាប់ចម្លងប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ | ចំនួន ០១ ច្បាប់ |
| ៩-លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់) | ចំនួន ០១ ច្បាប់ |

**ច- វិញ្ញាសាប្រឡង :**

*សម្រាប់ការប្រឡងចូលប្រភេទក្របខ័ណ្ឌ« **ខ** »*

១- វិញ្ញាសាវប្បធម៌ទូទៅ (*សម្រាប់បម្រើការងារនៅមន្ទីរពាណិជ្ជកម្ម*) ឬវិញ្ញាសាគីមីសាស្ត្រជីវរូបសាស្ត្រ (*សម្រាប់បម្រើការងារទីស្តីការក្រសួង*) មេគុណ ១ រយៈពេល ២ ម៉ោង

២- វិញ្ញាសាភាសាអង់គ្លេស មេគុណ ១ រយៈពេល ១ ម៉ោង៣០នាទី

*សម្រាប់ការប្រឡងចូលប្រភេទក្របខ័ណ្ឌ« **គ** »*

១- វិញ្ញាសាវប្បធម៌ទូទៅ *មេគុណ ១ រយៈពេល ២ម៉ោង*

២- វិញ្ញាសាភាសាអង់គ្លេស *មេគុណ ១ រយៈពេល ១ម៉ោង៣០នាទី*

៣- វិញ្ញាសាសេដ្ឋកិច្ចពាណិជ្ជកម្ម ឬវិញ្ញាសាដែលទាក់ទងនឹងមុខជំនាញដែលបេក្ខជនស្នើសុំ

ចុះឈ្មោះប្រឡងដូចបានកំណត់បញ្ជាក់ខាងលើ *មេគុណ ២ រយៈពេល ២ម៉ោង*

**ច- កាលបរិច្ឆេទ និង មណ្ឌលប្រឡង :**

- កាលបរិច្ឆេទប្រឡង: **ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១២**

*<u>ពេលព្រឹក</u> ចាប់ពីម៉ោង ៧,៣០ រហូតដល់ម៉ោង ១១,៣០នាទី វិញ្ញាសាវប្បធម៌ទូទៅ និងភាសាអង់គ្លេស*

*<u>ពេលរសៀល</u> ចាប់ពីម៉ោង ១៤,៣០ រហូតដល់ម៉ោង ១៦,៣០នាទី វិញ្ញាសាសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិញ្ញាសាតាមវិស័យជំនាញការងារ*

- មណ្ឌលប្រឡង ៖ នៅទីស្ដីការក្រសួងពាណិជ្ជកម្ម ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ក្នុងករណីចាំបាច់ពាក់ព័ន្ធទៅនឹងចំនួនបេក្ខជន ដែលនាំឲ្យមានការផ្លាស់ប្ដូរមណ្ឌលប្រឡង ឬថ្ងៃប្រឡង គណៈកម្មការនឹងធ្វើការជូនដំណឹងជាសាធារណៈនៅមុនថ្ងៃប្រឡងចំនួន ៧ថ្ងៃ។

ព័ត៌មានលម្អិតផ្សេងៗទៀត បេក្ខជនអាចមកទំនាក់ទំនងដោយផ្ទាល់នៅលេខាធិការដ្ឋាននៃគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួងពាណិជ្ជកម្ម នៅទីស្ដីការក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានបុគ្គលិក) រាល់ម៉ោងធ្វើការ។

**ប្រធានគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ**
**ចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ឆ្នាំ២០១២**
**និងជារដ្ឋលេខាធិការ**

**ទេីង សុធី**

**<u>ចម្លងជូន</u> ៖**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
*"ដើម្បីជូនជ្រាប"*
-គ្រប់អគ្គនាយកដ្ឋាន អង្គភាព មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
-ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
*"ដើម្បីជួយផ្សព្វផ្សាយ"*
-ឯកសារ-កាលប្បវត្តិ

សាធារណៈជនអាចពិនិត្យមើលក្នុងគេហទំព័រក្រសួងពាណិជ្ជកម្ម **<u>www.moc.gov.kh</u>**